ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ:..........២២៤/២៥...............ក.ប/ខ.ល

## សារលិខិតអបអរសាទរ

**សូមគោរពជូន**
**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន**
**ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំ និងភរិយា សូមសម្តែងនូវការអបអរសាទរ ជូនចំពោះ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែលត្រូវបាន **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់ដំឡើងឋានន្តរស័ក្តិ ថ្នាក់ «**នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស៥ នៃកងយោធពលខេមរភូមិន្ទ**»។

ការទទួលបាននូវការត្រាស់បង្គាប់ដំឡើងឋានន្តរស័ក្តិនេះ គឺពិតជាស័ក្តិសមនឹងវីរភាពដ៏អង់អាចក្លាហាន ប្រកបដោយសមត្ថភាព ទេពកោសល្យ ភាពជាអ្នកដឹកនាំ គុណសម្បត្តិដ៏បវរថ្លៃថ្លារបស់ **សម្តេចកិត្តិសង្គហបណ្ឌិត** ក្នុងបុព្វហេតុបម្រើសង្គមជាតិ និងជាថ្នាក់ដឹកនាំស្ត្រីដ៏ឆ្នើមនិងដ៏កម្រមួយរូប ប្រកបដោយគតិបណ្ឌិតខ្ពស់ វីរភាពអង់អាចក្លាហាន ដែលបានបូជាអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ក្នុងការបំពេញបេសកកម្ម កសាង និងការពារសន្តិភាព ស្ថិរភាព ឯករាជ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងបានទ្រទ្រង់និរន្តរភាពនៃការរីកចម្រើនរបស់ប្រទេសកម្ពុជា។ យើងខ្ញុំជឿជាក់យ៉ាងមុតមាំថា នៅក្នុងឋានៈជានាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស ៥ នៃកងយុទ្ធពលខេមរភូមិន្ទ **សម្តេចកិត្តិសង្គហបណ្ឌិត** នឹងបន្តបុព្វហេតុនៃបេសកកម្មដ៏ឧត្តុង្គឧត្តមថ្លៃថ្លា សម្រេចបាននូវសមិទ្ធផលថ្មីៗកាន់តែវិសេសវិសាលថែមទៀត ជាឧត្តមប្រយោជន៍ដល់ប្រទេសជាតិ និងរាជានិយមកម្ពុជា។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏មហាមង្គលាភិរម្យថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ ជូនចំពោះ **សម្តេចកិត្តិសង្គហបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រលាញ់** សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃអាទិត្យ ៣រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៥

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**រដ្ឋមន្ត្រី**

**ហេង សួរ**